ធ៧-០៣-០០២ ស.រ.ណ.ន

# សារាចរណែនាំ
# ស្តីពី
# ការផ្តល់និងការថតចម្លងឯកសារនៅពេលត្រួតពិនិត្យដល់ទីកន្លែង

១- ធនាគារត្រូវផ្តល់រាល់ព័ត៌មាននិងទិន្នន័យទាំងអស់តាមសំណើ ដល់អ្នកត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ក្នុងពេលត្រួតពិនិត្យដល់ទីកន្លែង។

២- កាតព្វកិច្ចនៃការសម្ងាត់វិជ្ជាជីវៈមិនអាចយកមកប្រើជាមូលដ្ឋាន សម្រាប់ការមិនបង្ហាញព័ត៌មានដល់អ្នកត្រួតពិនិត្យឡើយ។ ជាងនេះទៀត អ្នកត្រួតពិនិត្យដែលជាបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ត្រូវមានកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ និងមិនអាចផ្តល់ព័ត៌មានសម្ងាត់ទាំងឡាយដែលទទួលបានពីធនាគារពាណិជ្ជទៅបុគ្គលណាមួយឡើយ។

៣- ហេតុនេះ ធនាគារពាណិជ្ជទាំងអស់មិនអាចបដិសេធមិនផ្តល់ឯកសារ ឬព័ត៌មានតាមសំណើរបស់អ្នកត្រួតពិនិត្យឡើយ។

៤- ជាពិសេស ធនាគារត្រូវផ្តល់អ្នកត្រួតពិនិត្យនូវរាល់ព័ត៌មានគណនេយ្យ រាល់ឯកសារឥណទាន និងរាល់ព័ត៌មានទាំងអស់សម្រាប់ការវាយតម្លៃហានិភ័យ ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពចំណេញរបស់ធនាគារយ៉ាងត្រឹមត្រូវ។ ជាក់ស្តែង ព័ត៌មានទាំងនេះមិនត្រូវឱ្យមានខ្វះទេ។

៥- អ្នកត្រួតពិនិត្យអាចស្នើសុំថតចម្លងឯកសារ ឬព័ត៌មានទទួលបានពីធនាគារដែលត្រូវត្រួតពិនិត្យសម្រាប់ទុកជាឯកសារ។ អ្នកត្រួតពិនិត្យទទួលបានការអនុញ្ញាតឱ្យថតចម្លងឯកសារ ឬ ពីកុំព្យូទ័រ។

៦- រាល់ចំណាយដែលទាក់ទងនឹងការថតចម្លងព័ត៌មាន ឬឯកសារណាមួយជាចំណាយរបស់ធនាគារដែលត្រូវត្រួតពិនិត្យ។

៧- រាល់ការជំទាស់មិនផ្តល់ព័ត៌មាន ឬការថតចម្លងឯកសារណាមួយនឹងត្រូវរងការដាក់ទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា ៦៩ នៃច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅរបស់ធនាគារជាតិនៃកម្ពុជា។

៨- សារាចរនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣

**អគ្គនាយក**

ហត្ថលេខា និងត្រា: **គាល់ ណែអ៊ីម**